**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# ញត្តិគាំទ្រ

កាលពីព្រឹកថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥ នៅវិមានសន្តិភាព លោកជំទាវ Mereni Keleti Vakasiskakala តំណាងអង្គការសហប្រជាជាតិ បាននាំយកផែនទី UTM ខ្នាត ១/១០០ ០០០ ចំនួន១៨ផ្ទាំង ដែលតម្កល់ទុកនៅអង្គការសហប្រជាជាតិ មកប្រគល់ជូនរាជរដ្ឋាភិបាលកម្ពុជា តាមសំណើសុំខ្ចីរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដើម្បីធ្វើការផ្ទៀងផ្ទាត់ជាមួយផែនទីខ្នាត ១/១០០ ០០០ ផលិតដោយក្រុមភូមិសាស្ត្រឥណ្ឌូចិន ដែលរាជរដ្ឋា ភិបាលកម្ពុជាបាននិងកំពុងប្រើប្រាស់ក្នុងការកំណត់ព្រំដែនរវាងកម្ពុជា និងវៀតណាម។

ថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏ដូចជាមហាជនទូទៅ បានធ្វើការតាមដានយ៉ាងយកចិត្តទុកដាក់នូវព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រដ៏សំខាន់នេះ ហើយបានពិនិត្យឃើញថា ដំណើរការនៃការផ្ទៀងផ្ទាត់ផែនទីនេះបានប្រព្រឹត្តទៅប្រកបដោយតម្លាភាព ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ រួមមានជាអាទិ៍ តំណាងរាជរដ្ឋាភិបាលកម្ពុជា តំណាងគណបក្សប្រជាជនកម្ពុជា តំណាងគណបក្សសង្គ្រោះជាតិ តំណាងគណបក្សហ៊្វុនស៊ិនប៉ិច តំណាងក្រុមប្រឹក្សាធម្មនុញ្ញ តំណាងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងតំណាងរាជបណ្ឌិតសភាកម្ពុជា ហើយលទ្ធផលនៃការផ្ទៀងផ្ទាត់បានបង្ហាញឱ្យឃើញយ៉ាងច្បាស់ឥតប្រកែកបានថា ផែនទីដែលអង្គការសហប្រជាជាតិនាំមក និងផែនទីដែលរាជរដ្ឋាភិបាលកម្ពុជាកំពុងប្រើប្រាស់ គឺមានភាពដូចគ្នា។

លទ្ធផលនៃការផ្ទៀងផ្ទាត់នេះ គឺបានសបញ្ជាក់ឱ្យឃើញកាន់តែច្បាស់ថែមទៀតអំពីភាពត្រឹមត្រូវពិតប្រាកដនៃផែនទីដែលរាជរដ្ឋាភិបាលកម្ពុជាប្រើប្រាស់បច្ចុប្បន្ន និងបង្ហាញឱ្យឃើញកាន់តែច្បាស់អំពីនយោបាយបោកប្រាស់របស់ក្រុមជនអគតិមួយចំនួន ដែលតែងតែភូតកុហក បោកប្រាស់ មួលបង្កាច់ខុសពីការពិតមកលើ រាជរដ្ឋាភិបាលនាពេលកន្លងមក ក្នុងគោលបំណងបម្រើអាជីវកម្មនយោបាយដ៏ងប់ងល់របស់ខ្លួន ដោយមិនគិតអំពីផលប្រយោជន៍ដ៏ឧត្តុង្គឧត្តមរបស់ជាតិ និងមាតុភូមិ។

ជាថ្មីម្តងទៀត ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈទាំងអស់ សូមប្រកាសគាំទ្រយ៉ាងឱឡារិកចំពោះរាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលតែងតែបានបូជាកម្លាំងកាយ កម្លាំងចិត្ត និងប្រកាន់ភ្ជាប់នូវឧត្តមគតិស្នេហាជាតិដ៏ឧត្តុង្គឧត្តម ក្នុងការការពារបូរណភាពទឹកដី និងអធិបតេយ្យជាតិ ជាពិសេសក្នុងការដោះស្រាយបញ្ហាព្រំដែនជាមួយប្រទេសជិតខាង ប្រកបដោយការទទួលខុសត្រូវខ្ពស់ចំពោះជោគវាសនាប្រទេសជាតិ និងមាតុភូមិទាំងមូល។

ថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមធ្វើការថ្កោលទោសយ៉ាងដាច់អហង្ការ ចំពោះទង្វើរបស់ជនអគតិមួយចំនួនដែលតែងតែបានធ្វើការប្រឌិត និងចោទប្រកាន់មួលបង្កាច់ទាំងងងឹតងងល់នាពេលកន្លងមក ដើម្បីបម្រើនយោបាយប្រជាភិថុតរបស់ក្រុមខ្លួន មកលើកិច្ចខិតខំប្រឹងប្រែងយ៉ាងស្មោះសរ និងដើម្បីឧត្តមប្រយោជន៍ជាតិរបស់រាជរដ្ឋាភិបាលក្នុងការងារព្រំដែននេះ និងសូមអំពាវនាវដល់អាជ្ញាធរមានសមត្ថកិច្ច ចាត់វិធានការតាមច្បាប់ឱ្យបានម៉ឺងម៉ាត់បំផុត ដើម្បីពង្រឹងនីតិរដ្ឋ ក្នុងគោលបំណងថែរក្សាសន្តិភាព ស្ថិរភាពសង្គម និងសណ្តាប់ធ្នាប់សាធារណៈ។

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៥

រដ្ឋមន្ត្រី

**អ៊ិត សំហេង**

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩